**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងពាណិជ្ជកម្ម
អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ
នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
លេខ:...០៤៨.....................សហអ

**សូមគោរពជូន**
**ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**តាមរយៈ:** *លោកជំទាវរដ្ឋលេខាធិការ ទទួលបន្ទុក* DICO

**កម្មវត្ថុ:** *របាយការណ៍នៃកិច្ចប្រជុំ* SSC-TD-TRI *លើកទី ១៧*

**យោង:** - *លិខិតអញ្ជើញរបស់ក្រសួងពាណិជ្ជកម្មលេខ: ១៧១៦ ពណ.សហអ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៨*
- *កម្មវិធីកិច្ចប្រជុំប្រចាំឆ្នាំ ២០១៨ របស់* Trade SWAp

*សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយស សូមគោរពជម្រាបជូន* **ឯកឧត្តម ទេសរដ្ឋមន្ត្រី** *មេត្តាជ្រាបថា: អនុគណៈកម្មាធិការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម* SSC-TD-TRI (Sub-Steering Committee on Trade Development and Trade Related Investment) *បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាស លើកទី១៧ របស់ខ្លួនកាលពីថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០១៨ វេលាម៉ោង ៩:០០ ព្រឹក នៅក្រសួងពាណិជ្ជកម្ម ក្រោមអធិបតីភាព* **ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម** ។ *ខ្ញុំបាទសូមអនុញ្ញាត របាយការណ៍ជូននូវចំណុចសំខាន់ៗ នៃកិច្ចប្រជុំខាងលើនេះដូចខាងក្រោម ៖*

## I. បច្ចុប្បន្នភាពនៃកំណែទម្រង់ស៊ីជម្រៅរបស់ក្រសួងពាណិជ្ជកម្ម

**ឯកឧត្តម ទេសរដ្ឋមន្ត្រី** *បានធ្វើបច្ចុប្បន្នភាពជូនដល់ សមាជិក-សមាជិកា* SSC-TD-

TRI នូវកំណែទម្រង់ស៊ីជម្រៅរបស់ក្រសួងពាណិជ្ជកម្ម ដែលមានចំណុចគន្លឹះមួយចំនួន ដូចជា៖

- ✓ ការកែសម្រួលរចនាសម្ព័ន្ធរបស់ក្រសួងពាណិជ្ជកម្ម: ដើម្បីរៀបចំខ្លួនឲ្យបានទាន់ពេលវេលានៅពេលដែលកម្ពុជាចូលជាសហគមន៍អាស៊ាននៅឆ្នាំ ២០១៥ ក្រសួងពាណិជ្ជកម្មចាំបាច់ត្រូវធ្វើការកែសម្រួលនូវរចនាសម្ព័ន្ធរបស់ខ្លួន ដោយបង្កើតបន្ថែមនូវអគ្គនាយកដ្ឋានថ្មីចំនួន២គឺ (១) អគ្គនាយកដ្ឋានសេវាកម្ម (២) អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម និងនាយកដ្ឋានថ្មីចំនួន៨ (i) នាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិក (ii) នាយកដ្ឋាន អឺរ៉ុប មជ្ឈឹមបូព៌ា និងប៉ាស៊ីហ្វិក (iii) នាយកដ្ឋានអាមេរិក (iv) នាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន (v) នាយកដ្ឋាននាំចេញ-នាំចូល (vi) នាយកដ្ឋានកិច្ចការពិព័រណ៍ (vii) នាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ និង (viii) នាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម ។ អគ្គនាយកដ្ឋានសេវាកម្ម មាននាទីជាអ្នកផ្តល់សេវាកម្មសាធារណៈគ្រប់បែបយ៉ាងជូនអតិថិជន ។
- ✓ កំណែទម្រង់រដ្ឋបាលសាធារណៈ: ការជ្រើសរើសមន្ត្រីពីថ្នាក់អគ្គនាយក ដល់ប្រធាននាយកដ្ឋាន គឺឆ្លងកាត់ការដាក់ពាក្យនិងសម្ភាសន៍ជាមួយរដ្ឋលេខាធិការទាំង៧រូប និងចុងក្រោយគឺធ្វើសម្ភាសន៍ជាមួយរដ្ឋមន្ត្រី ។ រដ្ឋលេខាធិការ និងរដ្ឋមន្ត្រីធ្វើសម្ភាសន៍និងដាក់ពិន្ទុឲ្យបេក្ខជន ដាច់ដោយឡែកពីគ្នា រួចហើយទើបប្រជុំគ្នាវាយតម្លៃជ្រើសរើសបេក្ខជន ។
- ✓ ការបែងចែកបុស្តិ៍មន្ត្រីកាំកុងត្រូល: មន្ត្រីកាំកុងត្រូលត្រូវបានបែងចែកប៉ុស្តិ៍ធ្វើការតាមការចាប់ឆ្នោត ដែលត្រូវបានគេបែងចែកជាបួនតំបន់ធំៗ ។ តំបន់១ (ផែស្ងួតព្រលានយន្តហោះ កំពង់ផែក្រុងព្រះសីហនុ) ចាប់ឆ្នោតប្តូរទៅ តំបន់៤ (ក្រចេះ កំពង់ចាម មណ្ឌលគីរី រតនៈគីរី) ហើយអ្នកមកពីតំបន់៤ ចាប់ឆ្នោតផ្លាស់ប្តូរទៅកាន់តំបន់១វិញ ។ ការចាប់ឆ្នោតនេះ គឺផ្តល់យុត្តិធម៌និងតម្លាភាពដល់មន្ត្រីទាំងអស់ស្មើៗគ្នា ។
- ✓ ការត្រួតពិនិត្យទំនិញតាមច្រកព្រំដែនរបស់កាំកុងត្រូល: ការត្រួតពិនិត្យទំនិញតាមច្រកព្រំដែនគឺមិនត្រូវបានធ្វើឡើង ១០០% នោះទេ គឺត្រូវបានរៀបចំត្រួតពិនិត្យ

តាមប្រព័ន្ធគ្រប់គ្រងហានិភ័យ ។

- ✓ វិស័យអង្ករ: ក្រសួងពាណិជ្ជកម្មបានជួយសម្របសម្រួលក្នុងការរៀបចំបោះឆ្នោតជ្រើសរើសគណៈកម្មការដឹកនាំសហព័ន្ធស្រូវអង្ករកាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ ២០១៤ ។ ការបោះឆ្នោតបានជ្រើសរើសប្រធានមួយរូប និងអនុប្រធាន និងសមាជិកក្រុមប្រឹក្សាចំនួន ១១ រូប ។ ក្រុមការងារថ្មីនេះ និងត្រូវជួបពិភាក្សាជាមួយ **ឯកឧត្តម ទេសរដ្ឋមន្ត្រី** នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ ដើម្បីពិភាក្សាពីការជម្រុញការនាំអង្ករចេញ និងឈានទៅសម្រេចគោលដៅនាំអង្ករចេញអោយបាន ១លានតោន នៅឆ្នាំ២០១៥ ។
- ✓ អភិបាលកិច្ចល្អក្នុងវិស័យនាំចេញអង្ក: អ្នកនាំអង្ករចេញទាំងអស់ត្រូវបានចុះហត្ថលេខាលើក្រមសីលធម៌ "Code of Conduct" ដើម្បីជានាមិនអោយមានការបន្លំយកអង្ករពីប្រទេសដទៃមកប្រើស្លាកប្រទេសកម្ពុជាសម្រាប់ការនាំចេញ ។
- ✓ ការងារស្វ័យប្រវត្តិកម្មរបស់ក្រសួងពាណិជ្ជកម្ម: ក្រសួងកំពុងដំណើរការរៀបចំស្វ័យប្រវត្តិកម្មវិញ្ញាបនប័ត្រប្រភពដើម គេហទំព័រព័ត៌មានពាណិជ្ជកម្ម ស្វ័យប្រវត្តិកម្មការចុះបញ្ជីក្រុមហ៊ុន ស្វ័យប្រវត្តិកម្មនៃកម្មសិទ្ធិបញ្ញា ស្វ័យប្រវត្តិកម្មអនាម័យ និងភូតគាមអនាម័យ ។ល។
- ✓ E-commerce: ក្រសួងពាណិជ្ជកម្មកំពុងធ្វើសេចក្តីព្រាងច្បាប់ E-commerce ដោយបានការចូលរួមយ៉ាងសកម្មពីផ្នែកឯកជន ។ ច្បាប់នេះនឹងត្រូវធ្វើចប់សព្វគ្រប់នៅមុនដំណាច់ឆ្នាំ ២០១៤ នេះ ។
- ✓ ការទំនាក់ទំនង និងការផ្សព្វផ្សាយ: ក្រសួងពាណិជ្ជកម្មបានបង្កើតទំព័រ Facebook ហើយរហូតមកដល់ពេលនេះមានប្រិយមិត្តប្រមាណជាងបីម៉ឺននាក់។ ប្រិយមិត្តនៅក្នុង Facebook ត្រូវបានអញ្ជើញអោយចូលរួមក្នុងសិក្ខាសាលា ចែករំលែកព័ត៌មាន និងបទពិសោធន៍ដោយឥតគិតថ្លៃ ។ គេហទំព័ររបស់ក្រសួងពាណិជ្ជកម្មត្រូវបានកែសម្រួលប្រសើរជាងមុន។
- ✓ ការរៀបចំសិក្ខាសាលាស៊េរី (Seminar Series): ក្រសួងពាណិជ្ជកម្មបានរៀបចំសិក្ខាសាលាស៊េរី ក្នុងគោលបំណងផ្តល់ពត៌មានថ្មីៗ និងចែករំលែកបទពិសោធន៍

នានាដល់ផ្នែកឯកជន និងគ្រឹះស្ថានសិក្សា-ឧត្តមសិក្សា ។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងយ៉ាងទៀងទាត់ ដែលមានប្រធានបទ-វាគ្មិន ផ្សេងៗពីគ្នា ។ កាលពីខែមីនា ២០១៤ យើងបានរៀបចំសិក្ខាសាលាស៊េរី ស្ដីអំពី E-Commerce ដែលមានការចូលរួមប្រមាណជាង១ពាន់នាក់ ដែលជាសិស្ស និងមន្ត្រីក្រសួងពាណិជ្ជកម្ម ។ សិក្ខាសាលាលើកទីពីរនឹងរៀបចំនៅថ្ងៃស្អែក ដើម្បីពិភាក្សាអំពីសុវត្ថិភាពចំណីអាហារ សម្រាប់ឆ្នាំ ២០១៥-២០២០។

## II. របាយការណ៍វឌ្ឍនភាពក្នុងក្របខ័ណ្ឌ Trade SWAp

### ២.១) របាយការណ៍វឌ្ឍនភាពក្នុងក្របខ័ណ្ឌ TDSP

#### ក). ស្ថានភាពទូទៅនៃការអនុវត្តគម្រោង:

- គម្រោង TDSP បានចុះហត្ថលេខានៅថ្ងៃទី ១៤ ខែមករា ឆ្នាំ២០០៩ និងត្រូវបានអនុវត្តនៅថ្ងៃទី៩ ខែមីនា ឆ្នាំ២០០៩ ។ TDSP ត្រូវបានបន្តជាលើកទី ២ ឲ្យអនុវត្តរហូតដល់ថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០១៥ (គួរកត់សម្គាល់ផងដែរថា កាលពីលើកទី១ គម្រោង TDSP ត្រូវបានបន្តឲ្យ អនុវត្តត្រឹមថ្ងៃទី ៣១ ខែមករា ឆ្នាំ២០១៤)។
- គម្រោង TDSP បានទទួលថវិកាបន្ថែមពីសហគមន៍អឺរ៉ុបចំនួន $5,800,000 ក្នុងនោះ ៖
  - ✓ ថវិកាចំនួន $2,700,000 ត្រូវបានបែងចែកទៅឲ្យធនាគារពិភពលោក ក្នុងការអនុវត្តនូវគម្រោងមួយចំនួន នៅក្រោម Bank Executed Trust Fund (BETF) ។
  - ✓ ហើយថវិកាចំនួន $3,100,000 ត្រូវបានប្រគល់ជូនរាជរដ្ឋាភិបាល ក្នុងការអនុវត្តគម្រោង TDSP បន្តទៀត (Recipient Executed Trust Fund = RETF)
- ថវិកាខាងលើនេះ ត្រូវបានបែងចែកក្នុងការអនុវត្តគម្រោងថ្មីៗ មួយចំនួនដូចមានខាងក្រោម:

| No. | Project | Implementing Agency | Amount |
|---|---|---|---|
| 1 | Trade Training and Research Institute (TTRI) | MoC | $500,000 |
| 2 | CO Automation and Service Portal | MoC | $550,000 |
| 3 | Business Registration | MoC | $350,000 |
| 4 | SPS (Sanitary and Phyto-Sanitary) | MAFF | $200,000 |
| 5 | Implementation support and M&E | MoC | $1,500,000 |
| | **GRAND TOTAL** | | **$3,100,000** |

ខ). ការងារថវិកា:

- គិតចាប់ពីពេលអនុវត្តន៍គម្រោងដំបូង ពីឆ្នាំ ២០០៩ រហូតដល់ថ្ងៃ៣០ ខែមេសា ឆ្នាំ ២០១៤ នេះយើងបានធ្វើការចំណាយសរុបចំនួនតែ ៥៥% នៃជំនួយសរុប ($៨,៤២៣,៥១៧ ចេញពី $១៥,២៥០,០០០) ។
- ដោយបូករួមជាមួយថវិកាបន្ថែមចំនួន $3,100,000 នោះយើងមានថវិកាប្រមាណ $៧,០០៦,៤៨៣ ដែលត្រូវចំណាយក្នុងរយៈពេល ១០ ខែ ខាងមុខនេះ ដែលក្នុងនោះយើងត្រូវចំណាយប្រមាណ $600,000 ក្នុងមួយខែ ទើបចំណាយអស់ប្រាក់ជាង៧លានដុល្លារខាងលើនេះ ។

គ). ការងារលទ្ធកម្ម:

គ១). ការងារលទ្ធកម្មក្រោមកម្មវិធី TDSP

✓ កញ្ចប់ដែលកំពុងដំណើរការលទ្ធកម្មមាន៖

1. ការងាររៀបចំប្រព័ន្ធចេញវិញ្ញាបនប័ត្រប្រភពដើម (Certificate of Origin System -COS): ថ្ងៃផុតកំណត់សម្រាប់រៀបចំគម្រោងសំណើគឺនៅថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១៤។
2. កំពុងវាយតម្លៃលើការទិញនូវកម្មវិធីសម្រាប់ការចុះហត្ថលេខាអេឡិចត្រូនិច (E-signature) សម្រាប់គម្រោង ICT Master Plan
3. រៀបចំកិច្ចសន្យាការងារជាមួយទីប្រឹក្សាអន្តរជាតិផ្នែកលទ្ធកម្ម សម្រាប់ DICO
4. កំពុងវាយតម្លៃលើការជ្រើសរើសទីប្រឹក្សាអន្តរជាតិផ្នែកការកសាងសមត្ថភាព សម្រាប់គម្រោង TTRI (Trade Training and Research Institute)
5. កំពុងវាយតម្លៃលើការជ្រើសរើសទីប្រឹក្សាជាតិផ្នែកទំនាក់ទំនង សម្រាប់ DICO

✓ កញ្ចប់ដែលកំពុងផ្សព្វផ្សាយ៖

1. ជ្រើសរើសទីប្រឹក្សាជាតិផ្នែកពាណិជ្ជកម្មចំនួន ២ នាក់ (ថ្ងៃផុតកំណត់ថ្ងៃទី ១៣ ឧសភា ឆ្នាំ២០១៤)
2. ជ្រើសរើសទីប្រឹក្សាជាតិផ្នែកប្រតិបត្តិការ (ថ្ងៃផុតកំណត់ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ២០១៤)

3. ជ្រើសរើសទីប្រឹក្សាជាតិផ្នែកសម្របសម្រួលគម្រោងចំនួន ២ នាក់ (ថ្ងៃផុតកំណត់ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ២០១៤)
4. ជ្រើសរើសទីប្រឹក្សាអន្តរជាតិសម្រាប់ការងារកែសម្រួលការសរសេរ (ថ្ងៃផុតកំណត់ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ២០១៤)
5. ជ្រើសរើសសម្រាប់ការរៀបចំគេហទំព័រព័ត៌មានពាណិជ្ជកម្ម (ថ្ងៃផុតកំណត់ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ២០១៤)
6. ជ្រើសរើសទីប្រឹក្សាអន្តរជាតិសគ្រប់គ្រង (ថ្ងៃផុតកំណត់ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ២០១៤)
7. ជ្រើសរើសទីប្រឹក្សាជាតិផ្នែកសវនកម្មផ្ទៃក្នុង (ថ្ងៃផុតកំណត់ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ២០១៤)។

✓ កញ្ចប់ដែលនឹងត្រូវធ្វើលទ្ធកម្ម ៖

1. ជ្រើសរើសទីប្រឹក្សាជាតិ និងអន្តរជាតិសម្រាប់ ICT
2. ជ្រើសរើសទីប្រឹក្សាជាតិផ្នែកហិរញ្ញវត្ថុ
3. ជ្រើសរើសទីប្រឹក្សាជាតិផ្នែកលទ្ធកម្ម
4. ជ្រើសរើសទីប្រឹក្សាជាតិផ្នែកការកសាងសមត្ថភាព
5. ជ្រើសរើសទីប្រឹក្សាអន្តរជាតិផ្នែកច្បាប់
6. លទ្ធកម្មទិញសម្ភារៈការិយាល័យសម្រាប់ DICO, DoP (ការបណ្តុះបណ្តាលកំព្យូទ័រ និងភាសាអង់គ្លេស)
7. លទ្ធកម្មទិញគ្រឿងសង្ហារឹមសម្រាប់ DICO

គ២). ការងារលទ្ធកម្មក្រោមកម្មវិធី EIF

1. ជ្រើសរើសទីប្រឹក្សាអន្តរជាតិដឹកនាំការវាយតម្លៃគម្រោងពាក់កណ្តាលអាណត្តិសម្រាប់ គម្រោង CEDEP 1 (ថ្ងៃផុតកំណត់ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០១៤)
2. ជ្រើសរើសទីប្រឹក្សាជាតិសម្រាប់ការវាយតម្លៃគម្រោងពាក់កណ្តាលអាណត្តិសម្រាប់ គម្រោង CEDEP 1 (ថ្ងៃផុតកំណត់ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០១៤)

3. ជ្រើសរើសទីប្រឹក្សាជាតិផ្នែកត្រួតពិនិត្យ និងវាយតម្លៃ សម្រាប់គម្រោង CEDEP I (ថ្ងៃផុតកំណត់ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ២០១៤)

ឃ). ស្ថានភាពទូទៅនៃគម្រោង:

✓ មានគម្រោងចំនួន ៥ ដែលត្រូវបានបញ្ចប់ជាស្ថាពរ រួមមាន: Top Ten products (TPD), Development of Trade Curriculum (RSA), Value Chain Information Unit (TPD), Export and SME Training (TPD), and Capacity Building for DTSI (DTSI/MoC) ។

✓ ក្នុងត្រីមាសទី២នេះ មានគម្រោងចំនួន ៥ ត្រូវបានបិទជាផ្លូវការ រួមមាន:

| Project | Agency | Approved Budget | Actual Expense | Balance | % Expense |
|---|---|---|---|---|---|
| Customs Valuation | GDCE | 50,000 | 44,232 | 5,768 | 88% |
| Awareness Program on Customs in Cambodia | GDCE | 95,000 | 21,001 | 73,998 | 22% |
| GDCE Capacity Enhancement Programme | GDCE | 613,105 | 195,482 | 409,642 | 32% |
| Raising awareness on the Investment law | CDC | 195,860 | 93,740 | 102,119 | 48% |
| Enhancing IP Teaching and Training | NCIPR | 110,000 | 110,539 | (539) | 100.49% |
| **TOTAL:** | | | | **591,527** | - |

២.២) របាយការណ៍វឌ្ឍនភាពរបស់គម្រោង EIF Tier 1:

ក). គម្រោងពង្រឹងសមាហរណកម្មជំហានទី១ (EIF Tier 1):

✓ ចាប់ផ្តើមខែ កុម្ភៈ ២០១០

✓ បញ្ចប់នៅខែ មិថុនា ២០១៥

✓ ថវិកាគម្រោងដំណាក់កាលទី១: $909,900

- ✓ ថវិកាគម្រោងដំណាក់កាលទី2: $584,000
- ✓ ថវិកាគម្រោងដំណាក់កាលទី1&2: $ 1,493,900
- ✓ សរុបថវិកាគម្រោងដែលទទួលបាន: $910,605
- ✓ សរុបថវិកាដែលបានចំណាយ: $861,118 ។ ក្នុងនោះសម្រាប់ឆ្នាំ ២០១០ សរុបថវិកាចំណាយទាំងអស់មានចំនួន $12,844 ។ ឆ្នាំ២០១១ ចំណាយសរុបមានចំនួន $192,991 ។ ឆ្នាំ២០១២ ចំណាយសរុបមានចំនួន $313,290 ។ ឆ្នាំ២០១៣ ចំណាយសរុបមានចំនួន $284,826 ។ ឆ្នាំ២០១៤ គិតត្រឹមខែមីនា ចំណាយសរុបមានចំនួន $57,165 ។
- ✓ សកម្មភាពរីកចម្រើនសំខាន់ៗរបស់គម្រោងរួមមានដូចជា៖
  - ➢ គាំទ្រការបណ្តុះបណ្តាលភាសាអង់គ្លេសដល់មន្ត្រី DICO និងក្រសួងនានា
  - ➢ រៀបចំសិក្ខាសាលាស្តីពី ការពង្រីកពិពិធកម្មនាំចេញសម្រាប់មន្ត្រីកក្រសួងពាណិជ្ជកម្ម
  - ➢ បានគាំទ្រដល់ការរៀបចំប្រជុំ IC និង SSC
  - ➢ បានរៀបចំរបាយការណ៍ប្រចាំឆ្នាំ ២០១៣ របស់ EIF Tier1
  - ➢ បានបោះពុម្ពនូវរបាយការណ៍សង្ខេប CTIS 2014-2018 ជាភាសាខ្មែរ និងអង់គ្លេស
  - ➢ បានរៀបចំសម្ពោធជាផ្លូវការ CTIS 2014-2018
  - ➢ បានរៀបចំសម្ពោធជាផ្លូវការ CEDEP 2
  - ➢ បានធ្វើការជាមួយក្រុមបេសកម្មរបស់ EF & TFM.
  - ➢ បានរៀបចំកែសម្រួលផែនការសកម្មភាព និងផែនការថវិកា ព្រមទាំងផែនការកសាងសមត្ថភាពសម្រាប់ឆ្នាំ២០១៣-២០១៥។

### ខ). គម្រោងពង្រឹងសមាហរណកម្មជំហានទី២ (EIF Tier 2):

- ✓ CEDEP 1 ផ្តោតលើវិស័យចំនួន ៣ គឺ៖
  - វិស័យអង្ករ ដែលអនុវត្តគម្រោងដោយ IFC

- វិស័យសូត្រ ដែលអនុវត្តគម្រោងដោយ ITC និង
- M&E ដែលអនុវត្តគម្រោងដោយ DICO ។

✓ CEDEP 2 ផ្តោតលើវិស័យចំនួន ៣ គឺ៖

  - វិស័យជំឡូងមី ដែលអនុវត្តគម្រោងដោយ UNDP
  - វិស័យជលផល ដែលអនុវត្តគម្រោងដោយ UNIDO
  - រាជបណ្ឌិតសភាធ្វើម្ហូប ដែលអនុវត្តគម្រោងដោយ Shift 360 និង
  - M&E ដែលអនុវត្តគម្រោងដោយ DICO ។

✓ CEDEP 3: កិច្ចប្រជុំ SSC-TD-TRI លើកទី ១៦ បានស្នើឲ្យ DICO ធ្វើការពិនិត្យទៅលើវិស័យចំនួនបី (i) Light Manufacturing, (ii) Rubber និង (iii) Agro-processing ដែលអាចដាក់បញ្ចូលទៅក្នុង CEDEP 3 ។ ក្រុមប្រឹក្សាភិបាលរបស់ EIF នឹងរៀបចំកិច្ចប្រជុំមួយនៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៤ ដើម្បីពិនិត្យថាតើប្រទេសកម្ពុជាអាចដាក់គម្រោង CEDEP 3 បានដែរឬទេ? ក្នុងនាមជាលេខាធិការដ្ឋានរបស់ SSC-TD-TRI, DICO ស្នើសុំការអនុម័តពី SSC-TD-TRI ដើម្បីកំណត់វិស័យអាទិភាពលើវិស័យចំនួនបី [(i) Light Manufacturing, (ii) Rubber និង (iii) Agro-processing] ដើម្បីឲ្យក្រុមការងារបច្ចេកទេសរបស់ DICO ចាប់ផ្តើមធ្វើការនៅលើគម្រោង CEDEP 3 ។

## III. បទបង្ហាញរបស់ធនាគារពិភពលោក

សម្រាប់មូលនិធិប្រតិបត្តិដោយធនាគារពិភពលោក (Bank Executed Trust Fund - BETF) គឺចាំបាច់ត្រូវចំណាយអោយបាន ១សែនដុល្លារក្នុងមួយខែ ។ គម្រោងដែលគាំទ្រដោយមូលនិធិប្រតិបត្តិដោយធនាគារពិភពលោករួមមាន៖

- Support to the TDSP ($300,000)
- Non Tariff Measures (NTM) ($80,000)
- Support to National Logistic Blueprint ($400,000)
- Enhancing the Investment Environment (up to $450,000)
- Minimum Wages Capacity Building (up to $400,000)

- Investment Climate Assessment (already paid).

ធនាគារពិភពលោកបានស្នើសុំការអនុម័តពី SSC-TD-TRI នូវគម្រោងចំនួនពីរ ដូចខាងក្រោម:

១). Enhancing the Investment Environment

២). Minimum Wages Capacity Building

កិច្ចប្រជុំ SSC-TD-TRI បានធ្វើការអនុម័តនូវគម្រោងទាំងពីរខាងលើ តាមការស្នើសុំរបស់ធនាគារពិភពលោក ។

## IV. មតិចំណាប់អារម្មណ៍របស់តំណាង សហគមន៍អឺរ៉ុប

តំណាងសហគមន៍អឺរ៉ុបសំដែងនូវ មោទនភាពដោយបានចូលរួមក្នុងកម្មវិធីកែទម្រង់របស់ក្រសួងពាណិជ្ជកម្ម ។ មានការរីកចម្រើនដែលយើងមើលឃើញចំពោះមុខ ដូចជា ការកើនឡើងនៃចំណាត់ថ្នាក់របស់ប្រទេសកម្ពុជានៅក្នុង LPI (Logistics Performance Index) ហើយ ដោយឡែកក៏នៅមានផ្នែកខ្លះមានការយឺតយ៉ាវផងដែរ ។ EU មានបំណងបន្តជួយក្រសួងពាណិជ្ជកម្មក្នុងរយៈពេលមធ្យម ដោយផ្តោតទៅលើការកែទម្រង់អាស៊ាន ។ ចំពោះកញ្ចប់ Trust Fund ថ្មី EU នឹងបន្តពិគ្រោះពិភាក្សាជាមួយ Stakeholders បន្តទៀត ។

## V. បច្ចុប្បន្នភាពនៃការអនុវត្ត CEDEP

- ITC គាំទ្រលើវិស័យសូត្រ: ការអនុវត្តសកម្មភាពរបស់ ITC គឺកំពុងមានដំណើរការទៅយ៉ាងរលូន ។ ការអភិវឌ្ឍវិស័យសូត្រគឺចាំបាច់អោយមានក្រុមប្រឹក្សាភិបាលស្តីពីសូត្រ ។ ដូច្នេះ ITC សូមឲ្យក្រសួងពាណិជ្ជកម្ម និងស្ថាប័នពាក់ព័ន្ធជួយពន្លឿនការរៀបចំបង្កើតក្រុមប្រឹក្សាភិបាលស្តីពីសូត្រ អោយបានឆាប់ ។
- IFC គាំទ្រដល់វិស័យអង្ករ: IFC បានធ្វើលទ្ធកម្មលើការបង្កើតកម្មវិធីគ្រប់គ្រងម៉ាស៊ីនកិនស្រូវ ។ IFC បានធ្វើការណែនាំពីប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពចំណីអាហារ សុវត្ថិភាពការងារ និងសុខភាព ។

- UNDP គាំទ្រលើវិស័យជំឡូងមី: UNDP កំពុងដំណើរការធ្វើលទ្ធកម្មមួយចំនួន ដែលទាក់ទងនឹងការអនុវត្តសកម្មភាពរបស់ CEDEP II ។
- UNIDO គាំទ្រលើវិស័យជលផល: UNIDO បានរាយការណ៍ពីការអនុវត្តសកម្មភាពមួយចំនួនដែលបាននឹងកំពុងអនុវត្តនៅក្រោមការគាំទ្ររបស់ CEDEP។

## VI. ការអនុម័តនៅលើការកែសម្រួលគម្រោង និងគម្រោងថ្មី

ក). ការកែសម្រួលគម្រោង: មានគម្រោងចំនួនបួនដូចខាងក្រោមនេះ ត្រូវបានភ្នាក់ងារអនុវត្តគម្រោងស្នើសុំថវិកាបន្ថែម ។ បន្ទាប់ពីបានពិភាក្សាគ្នារួចមក SSC-TD-TRI បានអនុម័តទៅលើការស្នើសុំថវិកាបន្ថែមចំពោះគម្រោងទាំងបួននេះ ។ ដោយឡែកចំពោះ DoP គឺគ្រាន់តែធ្វើការកែសម្រួលបន្ទាត់ថវិកាប៉ុណ្ណោះ ។

| No | Project | MoU | Additional fund requested by IAs | Total Revised fund |
|---|---|---|---|---|
| 1 | MoC Core HR Functions (DoP) | $234,540 | **($67,810)** | $234,540 |
| 2 | ASYCUDA World System (GDCE) | $1,129,153 | **$269,600** | $1,398,753 |
| 3 | Development of Stronger IPR System (IPD) | $148,491 | **$67,699** | $216,190 |
| 4 | ICT Master Plan (MoC) | $1,798,200 | **$810,676** | $2,608,876 |

ខ). គម្រោងថ្មី: មានគម្រោងថ្មី ចំនួនពីរដូចខាងក្រោម ត្រូវបានស្នើសុំការអនុម័តពី SSC-TD-TRI ផងដែរ ដែលអង្គភាពអនុវត្តគម្រោងទាំងពីរនេះគឺ នាយកដ្ឋានចុះបញ្ជីនៃក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ បន្ទាប់ពីបានពិភាក្សាគ្នារួចមក SSC-TD-TRI បានអនុម័តជាគោលការណ៍ទៅលើគម្រោងទាំងពីរនេះ ដោយមានលក្ខខណ្ឌថាគម្រោងទាំងពីរនេះ ត្រូវដាក់ឆ្លងការឯកភាពពីសំណាក់គណៈកម្មការអនុវត្ត

គម្រោង IC (Implementation Committee) ជាមុនសិន ។ កិច្ចប្រជុំ IC គ្រោងនឹងរៀបចំឡើងនៅថ្ងៃទី ១០ មិថុនា ២០១៤ ខាងមុខនេះ ។

| Project Title | Streamlining and Automation of Business Registration | Automation of Phyto-Sanitary Certificates |
|---|---|---|
| Submitting Ministry/Agency | Department of Business Registration | General Directorate of Agriculture (GDA) |
| Main beneficiaries | The Ministry of Commerce, the Department of Business Registration<br><br>and Cambodian companies. | Ministry of Agriculture, Forestry and Fisheries, General Directorate of Agriculture and food exporters. |
| Expected Starting Date | June 2014 | June 2014 |
| Expected Completion Date | March 2015 | March 2015 |
| Proposed Budget (from RETF) | USD 399,398 | USD 392,800 |
| Resources from BETF | Consultant service | Consultant service |

## VII. អនុសាសន៍សម្រាប់កែលំអ ក្របខ័ណ្ឌអភិបាលកិច្ច នៃអភិក្រមគ្របដណ្ដប់វិស័យពាណិជ្ជកម្ម (Trade SWAp Governance Framework):

កិច្ចប្រជុំ SSC-TD-TRI លើកទី ១៦ បានណែនាំឲ្យ DICO និង WB រៀបចំកិច្ចប្រជុំជាមួយ Stakeholders ដើម្បីធ្វើការកែលំអ ក្របខ័ណ្ឌអភិបាលកិច្ចនៃអភិក្រមគ្របដណ្ដប់វិស័យពាណិជ្ជកម្ម ។ DICO និង WB បានរៀបចំកិច្ចប្រជុំនេះ នៅថ្ងៃទី ២៣ ឧសភា ២០១៤ និងបានដាក់ចេញនូវអនុស្សារណៈរួមគ្នាមួយ ដែលមានបួនកម្រិត ដូចខាងក្រោម:

### ១). អនុសាសន៍សម្រាប់កម្រិតគោលនយោបាយ:

a) រៀបចំប្រកាស ឬអនុក្រឹតថ្មីដែលឆ្លុះបញ្ចាំងទៅនឹងរចនាសម្ព័ន្ធរបស់រដ្ឋាភិបាល
b) អោយមានការចូលរួមពីវិស័យ ឯកជនច្រើនថែមទៀត
c) ប្រើប្រាស់បច្ចេកវិទ្យា ICT អោយមានច្រើនបំផុត
d) ស្វែងរកដៃគូអភិវឌ្ឍន៍ថ្មីថែមទៀត

e) ក្រសួងពាណិជ្ជកម្មគួរគាំទ្រដល់ការរៀបចំប្រជុំ SSC, IC នៅក្រោយពេលដែលកម្មវិធី TDSP/EIF ត្រូវបានបញ្ចប់ និង
f) លុបចោលក្រុមការងារសសរស្តម្ភ ។

២). កម្រិតស្ថាប័ន:

a) គួរមានការលើកទឹកចិត្តដល់ការចូលរួមគ្រប់ដំណាក់កាលនៃគម្រោង (ការរៀបចំបង្កើតគម្រោង ការអនុវត្តគម្រោង និងការវាយតម្លៃគម្រោង) ។
b) ភ្នាក់ងារអនុវត្តគម្រោង គួរអាចទទួលបានការគាំទ្រថវិកាពីដៃគូអភិវឌ្ឍន៍ (TDSP BETF) ដើម្បីជួលទីប្រឹក្សាក្នុងការជួយរៀបចំបង្កើតគម្រោងថ្មី ។

៣). កិច្ចសន្ទនាជាមួយដៃគូអភិវឌ្ឍន៍:

a) មានការឯកភាពដាក់ចេញនូវអាទិភាពជាមួយដៃគូអភិវឌ្ឍន៍ តាមរយៈការរៀបចំសិក្ខាសាលាប្រចាំឆ្នាំមួយ ហើយអាទិភាពនីមួយៗ គួរមានទំនាក់ទំនងទៅនឹងលទ្ធផលជាក់លាក់ ។
b) ស្វែងរកដៃគូអភិវឌ្ឍន៍ទាក់ទងនឹង ការអភិវឌ្ឍពាណិជ្ជកម្ម ដើម្បីចែករំលែកព័ត៌មាន និងអនុវត្តសកម្មភាពអោយស្រប ទៅនឹងយុទ្ធសាស្ត្រអាទិភាពរបស់រដ្ឋាភិបាល ។
c) គៀងគដៃគូអភិវឌ្ឍដែលធ្វើ សកម្មភាពទាក់ទងនឹងពាណិជ្ជកម្មអោយមកចូលរួមក្នុងអភិក្រម SWAp (តាមរយៈ ការចូលរួមចំណែកជាថវិកា ឬសម្ភារៈក៏ដូចជាដំណើរការត្រួតពិនិត្យ និងវាយ តម្លៃ) ។
d) គៀងគរដៃគូអភិវឌ្ឍន៍សម្រាប់គាំទ្រ ដល់ការអនុវត្តក្រោយឆ្នាំ ២០១៩ ។
e) ធ្វើអោយប្រសើរឡើងលើការទំនាក់ទំនងរវាង ក្រសួងពាណិជ្ជកម្ម និងដៃគូអភិវឌ្ឍន៍ ដើម្បីធ្វើអោយសម្រេចនូវសមិទ្ធិផលនៅក្រោមអភិក្រម ។
f) ផ្លាស់ប្តូរកិច្ចសន្ទនាពីការប្រតិបត្តិទៅជាការរៀបចំគម្រោង ការវាស់វែងពីភាពរីកចម្រើន ទស្សនៈវិស័យ យូរអង្វែង និងបញ្ហាយុទ្ធសាស្ត្រ ។ល។

៤). ការចូលរួមពីវិស័យឯកជន:

a) ធានាអោយមានការចូលរួមពីតំណាងវិស័យឯកជន ច្រើនថែមទៀត

b) ធ្វើការវាយតម្លៃពីសក្តានុពលភាពជាដៃគូជាមួយវិស័យឯកជន

c) បង្កើនការរៀបចំបង្កើតគម្រោងរួមគ្នាជាមួយវិស័យឯកជន

d) រៀបចំវគ្គបណ្តុះបណ្តាល ពីប្រធានបទទាក់ទងការនាំចេញ

e) ភ្ជាប់ជាមួយក្រុមការងារវេទិការាជរដ្ឋាភិបាល និងវិស័យឯកជន

f) អោយមានតំណាងសភាពាណិជ្ជកម្មនៅក្នុងកិច្ចប្រជុំ SSC-TD-TRI ។

ក្រោយពីបានពិនិត្យពិភាក្សា កិច្ចប្រជុំ SSC-TD-TRI បានឯកភាពទៅលើអនុស្សារណៈរួមគ្នានេះ និងបានណែនាំឲ្យគ្រប់ផ្នែកពាក់ព័ន្ធទាំងអស់ រួមទាំង DICO អនុវត្តនូវអនុស្សារណៈ ឲ្យបានជោគជ័យ ។

## VIII. អនុសាសន៍ និងការណែនាំរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី

ក្នុងនាមជាប្រធានអនុគណៈកម្មការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម (SSC-TD-TRI) **ឯកឧត្តម ទេសរដ្ឋមន្ត្រី** បានផ្តល់អនុសាសន៍ និងការណែនាំមួយចំនួនដូចខាងក្រោម:

- គាំទ្រទៅលើសំណើគម្រោងថ្មីរបស់ CDC ដោយផ្តោតទៅលើចំណុចសំខាន់ពីរគឺ Automation of Investor Tracking System និង Investor Aftercare ។
- ចំពោះគម្រោងថ្មីត្រូវផ្តល់ឯកសារជូនសមាជិក IC និង SSC ឲ្យបាន ១០ ថ្ងៃមុនកិច្ចប្រជុំពេញអង្គ ។
- សូមឲ្យភ្នាក់ងារអនុវត្តគម្រោង (IAs) ពន្លឿនការអនុវត្តគម្រោង និងចំណាយថវិកាគម្រោងអោយបានតាមផែនការ នៅមុនពេលបញ្ចប់កម្មវិធី TDSP នៅក្នុង ខែមីនា ឆ្នាំ២០១៥ ខាងមុខ ។
- បានកំណត់អាទិភាពទៅលើវិស័យចំនួនបី ដើម្បីជម្រុញអោយមានការរៀបចំគម្រោង CEDEP III ដែលវិស័យអាទិភាពទាំងនោះរួមមាន (i) Light Manufacturing, (ii)

Rubber និង (iii) Agro-processing ហើយព្រមទាំងជម្រុញអោយមានការចូលរួមពីផ្នែកឯកជន ។

- ជម្រុញការបង្កើត ក្រុមប្រឹក្សាសូត្រកម្ពុជា អោយបានឆាប់ ។
- កិច្ចប្រជុំ CEO Breakfast និងរៀបចំនៅថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០១៤ ។
- កាលបរិច្ឆេទសម្រាប់កិច្ចប្រជុំ SSC-TD-TRI បន្ទាប់គឺធ្វើឡើងនៅថ្ងៃទី ២១ ខែសីហា ឆ្នាំ ២០១៤ ។

អាស្រ័យហេតុនេះសូម **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់ ។

សូម **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ឧសភា ២០១៤

**ប្រធាននាយកដ្ឋាន**

ឈៀង ពេជ្រ

<u>ចម្លងជូន:</u>

- ខុទ្ទកាល័យ ឯកឧត្តមទេសរដ្ឋមន្ត្រី
- គ្រប់សមាជិក SSC-TD-TRI
- គ្រប់សមាជិក IC
- ឯកសារ - កាលប្បវត្តិ